# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម

សំណុំរឿង០០២ ■ របាយការណ៍លេខ ៤០ ■ សវនាការលើកស្តុតាង ■ សប្តាហ៍ទី ៣៥ ■ ១៨-១៩ តុលា ២០១២




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*លោកប្រធាន ហាក់ដូចជាកែប្រែវិធាននៃសវនាការនេះ យើងមិនទាន់ត្រៀមខ្លួន ហើយយើងមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងឯកសារ ដែលបានបង្ហាញជូនដោយភាគីនៅឡើយទេ ... យើងមិនចង់ចូលរួមនៅក្នុង សវនាការបែបនេះតទៅទៀត យើងនៅក្នុងដំណើរការដែលសិទ្ធិរបស់ជនជាប់ចោទ មិនត្រូវបានគោរព។*

- **លោក អាកទួរ វែកគែន**
  មេធាវីអន្តរជាតិការពារក្តី លោក ខៀវ សំផន
  (ឆ្លើយតបទៅនឹងប្រធានអង្គជំនុំជម្រះ)

## I. ទិដ្ឋភាពទូទៅ

បន្ទាប់ពីសម្រាកពិធីបុណ្យភ្ជុំបិណ្ឌ សវនាការបានចាប់ផ្តើមឡើងវិញនៅថ្ងៃប្រហស្បតិ៍ និងថ្ងៃសុក្រក្នុងសប្តាហ៍នេះ។ សហព្រះរាជអាជ្ញាបានបន្តដាក់បង្ហាញឯកសារភស្តុតាងបន្តពីសប្តាហ៍មុន និងឱកាសបន្ទាប់ជាវេនរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ទោះបីជាមានតែក្រុមមេធាវីការពារក្តីលោក **នួន ជា** បានដាក់ឯកសារក៏ដោយ ក៏ក្រុមមេធាវីការពារក្តីដទៃទៀតមានវត្តមាន ហើយធ្វើការជំទាស់ និងដាក់ជាសំណើនានាជាពិសេសពាក់ព័ន្ធនឹងវិធានក៏ដូចជាគោលបំណងនៃសវនាការលើឯកសារ។

សវនាការលើឯកសារ បានបញ្ចប់មុនការរំពឹងទុក ដូច្នេះ អង្គជំនុំជម្រះ បានកោះហៅដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ មកផ្តល់សក្ខីកម្មនៅរសៀលថ្ងៃសុក្រ។ លោកស្រី បានផ្តល់សក្ខីកម្មផ្តោតសំខាន់ទៅលើបទពិសោធន៍មុនពេល និងក្នុងកំឡុងពេលខ្មែរក្រហមឡើងកាន់ កាប់អំណាចជាពិសេសអំពីស្ថានភាពក្រុមគ្រួសាររបស់លោកស្រីដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥ និងការជម្លៀសលើកទីពីរពីខេត្តកណ្តាលនៅឆ្នាំ១៩៧៦។

## II. សង្ខេបនៃសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

លោកស្រី យឹម សុវណ្ណ គឺជាដើមបណ្ដឹងរដ្ឋប្បវេណីដំបូងដែលបានចូលខ្លួនមកផ្ដល់សក្ខីកម្មចំពោះមុខតុលាការអំពីបទពិសោធន៍នៃការជម្លៀសដោយបង្ខំនៅក្នុងសំណុំរឿងលេខ០០២/១/៣ កាលពីថ្ងៃសុក្រសប្ដាហ៍នេះ។ [1] សក្ខីកម្មរបស់លោកស្រី គឺផ្ដោតសំខាន់ទៅលើការជម្លៀសក្រុមគ្រួសាររបស់គាត់ចាកចេញពីទីក្រុងភ្នំពេញទៅកាន់ខេត្តកណ្ដាល និងការជម្លៀសបន្តទៅកាន់ខេត្តពោធិ៍សាត់។ ដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ ក៏ត្រូវបានសួរដេញដោលអំពីព័ត៌មានពាក់ព័ន្ធនឹងការសម្លាប់រង្គាល និងលក្ខខណ្ឌរស់នៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ។

### ក. ជីវប្រវត្តិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

ដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ កើតនៅឆ្នាំ១៩៦០នៅភូមិព្រះត្រាំងស្រុកស្អាង ខេត្តកណ្ដាល។ លោកស្រី និងក្រុមគ្រួសារបានទៅរស់នៅទីក្រុងភ្នំពេញនៅឆ្នាំ១៩៧២ដោយសារតែនៅក្នុងស្រុកភូមិរបស់គាត់មានការវាយប្រហារយ៉ាងខ្លាំងក្លារវាងកងទ័ព លន់ ណុល និងកងទ័ពខ្មែរក្រហម។ នៅទីក្រុងភ្នំពេញ ដំណើរ ជីវិតរបស់លោកស្រី យឹម សុវណ្ណ បានជួបបញ្ហាលំបាកជាខ្លាំង សូម្បីតែឱកាសសម្រាប់ការសិក្សាក៏គ្មានដែរ។

### ខ. ការជម្លៀសទៅភូមិភាគកណ្ដាល

ផ្អែកតាមសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ នៅពេលទាហានខ្មែរក្រហមចូលមកទីក្រុងភ្នំពេញនៅថ្ងៃទី១៧មេសា១៩៧៥ នាពេលនោះ ពុំមានការវាយប្រហារកើតឡើងទេ ព្រោះថាទាហាន លន់ ណុល បានបរាជ័យ និងចុះចាញ់អស់ហើយ។ លោកស្រី ក៏បានរៀបរាប់ឲ្យដឹងថាទាហានខ្មែរក្រហមបាន *"ប្រើអំពើហិង្សា"* ទៅលើទាហាន លន់ ណុល និងជនស៊ីវិលស្លូតត្រង់ទូទៅដោយវាយនឹងស្ទ័យកាំភ្លើង។ នៅរសៀលម៉ោងជាងបីថ្ងៃនោះ ជនស្លៀកពាក់ខ្មៅ បង់កក្រមាក្រហម ដៃកាន់កាំភ្លើង និងហៅខ្លួនគេថា *"សមមិត្តបង"* បានមកផ្ទះគាត់ និងបានឲ្យក្រុមគ្រួសារគាត់ចាកចេញពីផ្ទះ ដោយចោទប្រកាន់ថា *"ពួកគាត់គឺជាខ្មាំងនិងជាទាហាន លន់ ណុល។"* ដំបូងឡើយ ឪពុករបស់លោកស្រីបដិសេធមិនយល់ព្រមទេ ប៉ុន្តែក្រោយមក បានសម្រេចថាត្រូវតែចេញ នៅពេលទាហានខ្មែរក្រហមបានពន្យល់ពីមូលហេតុនៃបញ្ជារបស់ថ្នាក់លើ ដែលណែនាំប្រជាពលរដ្ឋឲ្យចាកចេញពីផ្ទះសម្បែង និងបានប្រាប់ថាអាមេរិកាំងនឹងទម្លាក់គ្រាប់បែកនៅទីក្រុងភ្នំពេញ ហើយការចាកចេញនេះគឺក្នុងរយៈពេលតែ៣ថ្ងៃប៉ុណ្ណោះ ដើម្បីបញ្ចៀសពីការទម្លាក់គ្រាប់បែកនេះ។ លោកស្រី និងក្រុមគ្រួសារមានពេលត្រឹមតែ១៥នាទីក្នុងការរៀបចំឥវ៉ាន់ចាកចេញពីផ្ទះខ្លួន។ លោកស្រីបានបន្តថានាពេលនោះទាហានខ្មែរក្រហមក៏បាន *"ចាត់វិធានការបង្ខំ"* ឬបាញ់សម្លាប់ជនដែលរឹងទទឹងមិនព្រមចាកចេញតាមបញ្ជា។ [2] ដូច្នេះ លោកស្រី និងក្រុមគ្រួសារ *"គ្មានជម្រើសផ្សេងក្រៅពីការចាកចេញ"* ឡើយ។

យោងតាមលោកស្រី យឹម សុវណ្ណ ទាហានខ្មែរក្រហមពុំបានយកចិត្តទុកដាក់ចំពោះអ្នកជម្ងឺនៅតាមមន្ទីរពេទ្យនានា ឬអ្នកត្រូវការការព្យាបាលនោះទេ។ លោកស្រីបានឲ្យដឹងថានៅមន្ទីរពេទ្យបុរីកីឡា ដែលជាមន្ទីរពេទ្យរបស់របប លន់ ណុល ទាហានខ្មែរក្រហមបានប្រព្រឹត្តទៅលើទាហានដែលមានរបួស ដោយការរុញច្រានពួកគេផ្កាប់ទៅនឹងដី និងទុកពួកគេចោលរហូតដល់ដាច់ខ្យល់ស្លាប់។ លោកស្រីលើកឡើងថា៖

> *នៅថ្ងៃ១៧មេសា១៩៧៥អ្នកជម្ងឺ និងចាស់ជរាពុំត្រូវបានខ្មែរក្រហមផ្តល់ការគាំពារទាល់តែសោះ។ពួកគេធ្វើ ដំណើរចាកចេញ និងមើលថែទាំខ្លួនដោយខ្លួនឯង។ អ្នកដែលអាចធ្វើដំណើរដោយខ្លួនឯងគឺពុំប្រឈមបញ្ហាអ្វីទេ ប៉ុន្តែប្រសិនបើមិនអាច ឬបដិសេធមិនចាកចេញពួកគេអាចនឹងជួបជោគវាសនាមិនល្អ។*

លោកស្រី បានធ្វើដំណើរចេញទីក្រុងភ្នំពេញទៅកាន់ស្រុកស្ទឹងកំពង់ទួល នៅក្នុងស្ថានភាពច្របូកច្របល់ និងភាពភិតភ័យ។ លោកស្រីបានប្រទះឃើញសាកសពទាហាន និងជនស៊ីវិលជាច្រើននៅតាមដងវិថី និង បានឃើញប្រជាជនមាសមីដេរដាសនៅតាមផ្លូវ ប្រពន្ធព្រាត់ប្តី ម្តាយព្រាត់កូន និងពេលខ្លះមានការរត់ជាន់គ្នាទៀតផង។ ស្ថានភាពទូទៅនៃការភៀសខ្លួនគឺជួបបញ្ហាលំបាកជាខ្លាំងដោយសារតែ *"ប្រាក់កាសត្រូវបានលែងចរាចរ មិនមានចំណីអាហារគ្រប់គ្រាន់ និង មិនមានទឹកទទួលទាន។"* លោកស្រីត្រូវបានតម្រូវឲ្យស្នាក់ នៅស្រុកស្ទឹងកំពង់ទួលប្រហែលជា១សប្តាហ៍ មុននឹងបន្តដំណើរទៅកាន់ឃុំភូទីបានស្រុកកោះខ្ទុំ ខេត្តកណ្តាលដែលចំណាយពេលធ្វើដំណើរជាង១ខែ។

## គ. ការប្រព្រឹត្តទៅលើ "ប្រជាជន ១៧មេសា" នៅឃុំភូទីបាន

លោកស្រី យឹម សុវណ្ណ បានពិពណ៌នាយ៉ាងលម្អិត ពីដំណើរជីវិតដ៏លំបាកវេទនារបស់ *"ប្រជាជន១៧មេសា"* និងមានស្ថានភាពផ្ទុយស្រឡះពី *"ប្រជាជនមូលដ្ឋាន"* នៅពេលពួកគេបានមកដល់ភូមិទី៥ ឃុំភូទីបាន នៅខែឧសភាឆ្នាំ១៩៧៥។[3] លោកស្រី បានស្នាក់នៅភូមិទី៥ប្រហែលជា៦ខែ ហើយទោះបីជាឪពុកមា របស់លោកស្រី បានស្គាល់ប្រជាជនមូលដ្ឋាននៅទីនោះក៏ដោយ ក៏ក្រុមគ្រួសាររបស់លោកស្រីនៅតែជួបបញ្ហាជាច្រើន៖

> *ពួកគេបានសុំសំលៀកបំពាក់ និងវត្ថុមានតម្លៃតាមតែចិត្តពួកគេចង់បាន។ ពួកគេមិនចូលចិត្តពួកយើង ទេ។ ពួកគេបានឆែកឆេររករបស់មានតម្លៃ និងសម្តែងការស្អប់ខ្ពើមយើងជាខ្លាំង។ ពួកគេបានបង្ខំឲ្យ យើងធ្វើការជាទម្ងន់ ប៉ុន្តែមិនផ្តល់ឧបករណ៍ប្រើប្រាស់ និងស្តីបន្ទោសយើងថា ប្រជាជន១៧មេសា គឺ ជាជនខ្ជិលច្រអូស និងជាមនុស្សអាក្រក់...ខ្ញុំព្យាយាមធ្វើការរហូតទាល់តែធ្លាក់ខ្លួនឈឺ ប៉ុន្តែពួកគេ បានបង្ខំឲ្យខ្ញុំដេកហាល ថ្ងៃនិងស្តីបន្ទោសថាខ្ញុំមានជម្ងឺមនោគមវិជ្ជា មិនមែនជាជម្ងឺក្តៅខ្លួនពិតប្រាកដទេ។*

នៅឃុំភូទីបាន លោកស្រី យឹម សុវណ្ណ និងក្រុមគ្រួសារ ត្រូវសរសេរប្រវត្តិរូបសង្ខេប និងតម្រូវឲ្យធ្វើស្រែ។ ចំពោះប្រជាជនមូលដ្ឋាន ពួកគេអាចទុកដាក់ស្រូវអង្ករសម្រាប់តម្រូវការផ្ទាល់ខ្លួន

ចំណែកប្រជាជន១៧មេសា បែរជាទទួលរបបអាហារជំនួសវិញ។ នៅពេលមានសំណួរថាតើមូលហេតុអ្វីបានជាប្រជាជន១៧មេសា ត្រូវបានប្រព្រឹត្តខុសគ្នាពីប្រជាជនមូលដ្ឋានលោកស្រី យឹម សុវណ្ណ បានឆ្លើយតបថា៖

> *តាមដែលខ្ញុំដឹង ប្រជាជន១៧មេសាត្រូវបានចាត់ទុកថាជាសត្រូវរបស់អង្គការ ចំណែកឯប្រជាជនមូលដ្ឋាន គឺជាប្រជាជនរបស់បដិវត្តន៍។ ប្រជាជន១៧មេសាត្រូវបានចាត់ទុកថាជាសត្រូវ ជាជនសក្តិភូមិ ជាជនមូលធននិយម។ ខ្ញុំមិនយល់ទាល់តែសោះ ថាហេតុអ្វីមានការប្រព្រឹត្តខុសគ្នាបែបនេះ។ ពួកយើងមិនមែនជាពួកមូលធននិយម ឬជាសក្តិភូមិនោះទេ។ ពួកយើងក៏ជាប្រជាជនក្រីក្រនៅក្នុងប្រទេសកម្ពុជាដែរ។*

លោកស្រី យឹម សុវណ្ណ ក៏បានរៀបរាប់ពីការចូលរួមក្នុងកិច្ចប្រជុំស្វ័យទិតៀន ដែលនាពេលនោះលោកស្រីត្រូវបានគេរិះគន់ថា *"ជាជនខ្ជិលច្រអូសនឹងការងារ"* និង នៅក្នុងកិច្ចប្រជុំគឺមានតែប្រជាជនមូលដ្ឋានទេ ដែលធ្វើការរិះគន់ទៅលើប្រជាជន១៧មេសា។

### ១. ការធ្វើទារុណកម្ម និងការសម្លាប់នៅមន្ទីរសន្តិសុខ១៥ និងវាលពិឃាតកោះគោ

លោកស្រី យឹម សុវណ្ណ បានធ្វើការបញ្ជាក់ឡើងវិញ តាមកំណត់ហេតុយកចម្លើយរបស់សហចៅក្រមស៊ើបអង្កេត ថាប្រជាជនពិតជាត្រូវបានចងស្លាបសេកទៅក្រោយ និងដឹកបញ្ជូនទៅមន្ទីរសន្តិសុខ១៥។ នៅក្នុងកំណត់ហេតុយកចម្លើយ លោកស្រីបានពន្យល់ថាប្រជាជនត្រូវបានចោទប្រកាន់ថា *"ជាខ្មាំងសត្រូវ"* និង ចាប់បញ្ជូនទៅមន្ទីរសន្តិសុខដែលជាកន្លែង *"ពួកគេមិនសង្ឃឹមថានឹងមានជីវិតរស់"* និង *"បាត់ខ្លួនជាបន្តបន្ទាប់។"* សក្ខីកម្មលោកស្រីចំពោះមុខតុលាការ លោកស្រីបានលើកឡើងថា ចម្ងាយពីខ្ទមរបស់គាត់ ដែលមានទីតាំងនៅជិតទន្លេ គាត់អាចមើលឃើញប្រជាជននៅភូមិផ្សេងត្រូវបានចងស្លាបសេក និងបញ្ជូនតាមទូកទៅមន្ទីរសន្តិសុខ[4] ប៉ុន្តែលោកស្រីមិនដែលប្រទះឃើញដោយផ្ទាល់ភ្នែកពីការកាប់សម្លាប់ នោះទេបើទោះបីជាគាត់តែងតែធ្វើដំណើរឆ្លងកាត់មន្ទីរសន្តិសុខ១៥ នៅពេលគាត់ទៅធ្វើស្រែក៏ដោយ។

លោកស្រីក៏បានបញ្ជាក់ពីទីតាំងកោះគោ គឺមានចម្ងាយប្រមាណជា៣០គ.ម ពីភូមិរបស់គាត់នៅស្រុកស្អាង។ លោកស្រីទទួលបានព័ត៌មានក្រោយមកថា កោះគោគឺជាវាលពិឃាតមនុស្ស។

## ឃ. ការជម្លៀសទៅខេត្តពោធិ៍សាត់

នៅដើមឆ្នាំ១៩៧៦ លោកស្រី យឹម សុវណ្ណ និងក្រុមគ្រួសារត្រូវបានជម្លៀសចេញពី ឃុំភូទីបាន។ លោកស្រីបានរៀបរាប់ថា ពួកគាត់មិនមានបំណងចាកចេញពីឃុំនេះទេ ប៉ុន្តែដោយទទួលដំណឹងថា ប្រសិនបើពួកគាត់ចចេសរឹងរូសមិនព្រមចេញ ពួកគាត់នឹងត្រូវបញ្ជូនទៅមន្ទីរសន្តិសុខ១៥។ មេកងនារី បានប្រាប់គាត់ថា *"នេះគឺជាការជម្លៀសលើកទី២"* ពីឃុំភូទីបាន ហើយមានតែប្រជាជន១៧មេសា ប៉ុណ្ណោះ ដែលត្រូវបានបង្ខំឲ្យជម្លៀសចេញព្រោះពួកយើងត្រូវបានចាត់ទុកថាជាខ្មាំង។ ដើមបណ្តឹងរដ្ឋប្បវេណី បន្តរៀបរាប់ថា លោកស្រី បានធ្វើដំណើរយ៉ាងលំបាកលំបិនចាកចេញពីឃុំភូទីបាន ទៅសហករណ៍*ក្បាលឈើពួក* ដែលមាន

ទីតាំងនៅឃុំ៩ ខេត្តពោធិ៍សាត់។ ក្រុមគ្រួសាររបស់លោកស្រីពុំអាចទិញទំនិញទៅតាមតម្រូវការ បានទេ ដោយសារតែប្រាក់កាសឈប់ធ្វើចរាចរតាំងពីថ្ងៃ១៧មេសា១៩៧៥។ នៅពេលនោះពួកគេទទួលបាន របប អង្ករ៣គីឡូក្រាម និងនំប៉័ងបន្តិចបន្តួចសម្រាប់ការធ្វើដំណើរតាមផ្លូវ និងទទួលទានទឹកត្រពាំង។ ក្រុមគ្រួសាររបស់លោកស្រី មិនមានលាក់ទុកអ្វីក្រៅពីរបស់ដែលចែកឲ្យនោះទេ ប៉ុន្តែគ្រួសារដទៃបានលាក់ចំណីអាហារសម្រាប់ផ្គត់ផ្គង់ខ្លួនឯង។ ម្តាយរបស់លោកស្រី មិនអាចមើលថែប្អូនប្រុសបង្កើតខ្លួនបានទេ ដោយសារតែគាត់ *"ពុំមានទឹកដោះគ្រប់គ្រាន់ក្នុងការបំបៅកូន ព្រោះគាត់ស្គមស្គាំង និងហេវហត់យ៉ាងខ្លាំង។"* នៅពេលទៅដល់ទីតាំងថ្មីលោកស្រី និងក្រុមគ្រួសារទទួលបានកូនខ្ទមមួយសម្រាប់ការស្នាក់នៅ ប៉ុន្តែក្រោយមកពួកគេ ត្រូវបានបំបែកឲ្យទៅធ្វើការនៅកន្លែងផ្សេងៗ។

## ១. ការស្លាប់សមាជិកគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅសហករណ៍ក្បាលឈើពួក

លោកស្រី យឹម សុវណ្ណ បានរៀបរាប់យ៉ាងលម្អិតអំពីការស្លាប់របស់ឪពុកលោកស្រីនៅចុងឆ្នាំ១៩៧៨។ ឪពុករបស់លោកស្រី ត្រូវបានចោទប្រកាន់ថាជាសត្រូវរបស់បក្ស។ គាត់ត្រូវបានចងបណ្តើរយកទៅ*មន្ទីរសន្តិសុខ៧* នៅឯបន្ទាយយួន។[5] លោកស្រីមិនបានឃើញដោយផ្ទាល់ភ្នែកពីការសម្លាប់ឪពុកនោះទេ ប៉ុន្តែមិត្តភ័ក្តិរបស់ប្អូនស្រី បានប្រាប់លោកស្រីថាឪពុករបស់គាត់ត្រូវបានគេសម្លាប់ហើយ។ នៅពេលទទួលដំណឹង នេះភ្លាមលោកស្រី យឹម សុវណ្ណ បាន *"ទួញយំសោកជាខ្លាំង"* ប៉ុន្តែអ្នកភូមិបានប្រាប់គាត់កុំឲ្យយំសោកបែបនេះ ប្រសិនបើគេឃើញគាត់អាចត្រូវចោទប្រកាន់ថាជាជនក្បត់។

លោកស្រី ក៏បានលើកឡើងពីការស្លាប់របស់ប្អូនស្រី ដែលនាងបានរស់នៅក្នុងកងកុមារនៅ*មន្ទីរសន្តិសុខ៧*។ នាពេលនោះកុមារដែលធ្វើការនៅមន្ទីរសន្តិសុខ៧ គឺទទួលបានតែបបរាវ១២ស្លាបព្រាប៉ុណ្ណោះក្នុងមួយពេល។ ប្អូនស្រីរបស់លោកស្រី ត្រូវបានចោទប្រកាន់ថាជាខ្មាំងព្រោះនាងលួចបូតស្រូវ ហើយក៏ត្រូវបានចាប់ខ្លួន។ លោកស្រី យឹម សុវណ្ណ បានបន្ថែមថាបុរសម្នាក់ ដែលជាអតីតគ្រូបង្រៀនខ្លួន បានគម្រាមរកសម្លាប់ប្អូនស្រី គាត់ប្រសិនបើម្តាយលោកស្រីពុំព្រមប្រគល់ជញ្ជៀនទៅឲ្យពួកគេទេ។ ម្តាយលោកស្រីបានបដិសេធមិនព្រម ប្រគល់ជញ្ជៀនទៅឲ្យបុគ្គលនោះទេដូច្នេះហើយប្អូនស្រីគាត់ក៏ត្រូវបានចាប់បញ្ជូនទៅ*មន្ទីរសន្តិសុខ៧* និង បញ្ជូនបន្តទៅ*មន្ទីរសន្តិសុខ៨* ហើយបាត់ខ្លួនរហូតមក។[6]

## ២. វាលពិឃាតទួលពោធិ៍ជ្រៃ

លោកស្រី យឹម សុវណ្ណ បានឲ្យដឹងថាគាត់បានទទួលព័ត៌មានថាទាហាន **លន់ ណុល** ត្រូវបានយកទៅសម្លាប់នៅវាលពិឃាតទួលពោធិ៍ជ្រៃ ខេត្តពោធិ៍សាត់ កាលពីខែមេសា១៩៧៥។[7] លោកស្រីបានរៀបរាប់ថា៖

> *ខ្ញុំបានទទួលដំណឹងពីអ្នកភូមិថា ទីតាំងនេះគឺជាកន្លែង ដែលពួកខ្មែរក្រហមសម្លាប់ទាហាន លន់ ណុល ... ទាហានរបស់របបចាស់ត្រូវធ្វើការឲ្យរបបថ្មី ហើយជនរងគ្រោះទាំងនោះធ្វើតាមការណែនាំ ដែលតាមពិតពួកគេត្រូវបានបញ្ជូនតាមរថយន្តទៅកាន់វាលពិឃាត។ ការសម្លាប់នេះធ្វើ ឡើងនៅកំឡុងខែមេសា១៩៧៥ ដែលចំណាយពេលប្រហែលជាកន្លះខែ។*

ទោះបីជាលោកស្រីពុំបានដឹងអំពីចំនួនពិតប្រាកដនៃការស្លាប់របស់ទាហាន **លន់ ណុល** ក៏គាត់បានប្រាប់ថា គាត់ធ្លាប់បានដើរឆ្លងកាត់តំបន់នោះនៅពេលគាត់ទៅរកស្បូវប្រក់ដំបូងនៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧។ លោកស្រីបន្តថាអ្នកភូមិបានប្រាប់គាត់ជាញឹកញាប់ថា *"មនុស្សទាំងឡានៗ"* រួមទាំងមន្ត្រីរដ្ឋការរបបចាស់ ក៏ត្រូវបានគេដឹកយកទៅសម្លាប់ចោលដែរ។

## III. បញ្ហាផ្នែកច្បាប់ និងនីតិវិធី

សប្តាហ៍នេះ បណ្តាភាគីបានបន្តដាក់បង្ហាញឯកសារដែលពួកគេមានគោលបំណងប្រើប្រាស់នៅក្នុងដំណើរការ សវនាការវគ្គទី៣នៃសំណុំរឿង០០២/១។ បន្ទាប់ពីសហព្រះរាជអាជ្ញាបានបញ្ចប់ការដាក់បង្ហាញនូវឯកសារភស្តុតាងរបស់ខ្លួនមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានដាក់បន្ថែមភស្តុតាងពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា និងប្រព័ន្ធទំនាក់ទំនងរបស់បក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ។ [8] ចំណែកឯក្រុមមេធាវីការពារក្តីលោក **នួន ជា** គឺជាក្រុមមេធាវីតែមួយគត់ ដែលដាក់ឯកសារភស្តុតាង របស់ខ្លួន ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ក្រុមមេធាវីការពារក្តីនានា បានលើកឡើងនូវការជំទាស់ និងស្នើសុំការ ស្រាយបំភ្លឺអំពីប្រភេទឯកសារដែលអាចដាក់បង្ហាញនៅក្នុងតុលាការ និងគោលបំណងនៃដំណើរការសវនាការលើឯកសារ។

### ក. ឯកសារដែលដាក់បង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញា និងការជំទាស់របស់មេធាវីការពារក្តី

កាលពីសប្តាហ៍មុន សហព្រះរាជអាជ្ញា បានចាប់ផ្តើមដាក់បង្ហាញឯកសារដែលលើកឡើងពីរចនាសម្ព័ន្ធប្រព័ន្ធទំនាក់ទំនង និងកិច្ចប្រតិបត្តិការនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យព្រមទាំងការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តនៅថ្នាក់មូលដ្ឋាន។ នៅព្រឹកថ្ងៃព្រហស្បតិ៍សប្តាហ៍នេះព្រះរាជអាជ្ញា វ៉ាំងសង់ វ៉ាយដ៏ ដេស្មាឯល បានបន្តដាក់បង្ហាញឯកសារដែលបានមកពីក្រសួងពាណិជ្ជកម្មក្រសួងសង្គមកិច្ច និងក្រសួងឃោសនាការ។ ឯកសារទាំងនោះបានពិពណ៌នាអំពីសមាសភាពការងារ និងទំនាក់ទំនងជាមួយរដ្ឋាភិបាលបក្សកុម្មុយនីស្ត។ ជាពិសេស ព្រះរាជអាជ្ញាបានបន្តបង្ហាញឯកសារដែលបានមកពី ក្រសួងពាណិជ្ជកម្មចំនួន២៨ច្បាប់ ដាក់ជូនចំពោះ *"បងហែម"* ឬជនជាប់ចោទ **ខៀវ សំផន**។ ឯកសារទាំងនេះបានបញ្ជាក់ពីការដឹកជញ្ជូនសម្ភារៈយោធា និងការនាំចូលស្រូវអង្ករ [9] ព្រមទាំងការកំណត់អត្តសញ្ញាណការឃុំឃាំង និងការសម្រិតសម្រាំង *"សត្រូវស៊ីរូងផ្ទៃក្នុង"* នៅក្នុងក្រសួង។[10] ជាបន្ទាប់ ព្រះរាជអាជ្ញា វ៉ាំងសង់ បានបន្តបង្ហាញឯកសារ ដែលពាក់ព័ន្ធនឹងក្រសួងសង្គមកិច្ចរួមមានកំណត់ហេតុ កិច្ចប្រជុំដែលលើកឡើងពីជម្ងឺរាតត្បាត (ដែល ប៉ុល ពត ថ្លែងថា ជម្ងឺនេះគឺឆ្លងរាតត្បាតពីប្រជាជន១៧មេសា) ក៏ដូចជាភាពខុសគ្នារវាងកសិករនិងជនបដិវត្តន៍។ កំណត់ត្រាសង្ខេបនៃកិច្ចប្រជុំដទៃទៀត បានលើកឡើងពីកិច្ចប្រជុំស្ម័យទិតៀនដែលរៀបចំដោយបក្សកុម្មុយនីស្តកម្ពុជា និងព័ត៌មានអំពីសកម្មភាពរបស់សត្រូវវៀតណាមដែលនឹងត្រូវធ្វើការវាយប្រហារ។ [11] ព្រះរាជអាជ្ញាបានបង្ហាញឯកសារចុងក្រោយ គឺកំណត់ត្រាកិច្ចប្រជុំថ្ងៃទី១១មករា១៩៧៦

ដែលប្រព្រឹត្តទៅនៅក្រសួងឃោសនាការ។ អ្នកចូលរួម រួមមានដូចជា ប៉ុល ពត- **អៀង សារី**- **ខៀវ សំផន** - និងរដ្ឋមន្ត្រីក្រសួង ឃោសនាការ ហ៊ូ នឹម ដោយពិភាក្សាលើបញ្ហាការប្រកាសផ្សាយតាមវិទ្យុ។

ចំណែកព្រះរាជអាជ្ញាជាតិ ស៊ុង ឆវ័ន្ត បានបន្តបង្ហាញឯកសារដែលលើកឡើងពីប្រព័ន្ធទំនាក់ទំនងនៅក្នុងរបបនោះដើម្បីឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធ និងសេចក្តីសម្រេចនានារវាងថ្នាក់តំបន់ និងថ្នាក់មជ្ឈិម ព្រមទាំងពីថ្នាក់តំបន់ទៅថ្នាក់ស្រុក។ ឯកសារទាំងនេះពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធវិទ្យុ និងទូរសារនៅពេលមានសង្គ្រាមក្នុងការទំនាក់ទំនង និងពិភាក្សាអំពីសកម្មភាពរបស់ *"ខ្មាំងស៊ីរូងផ្ទៃក្នុង"*។ ព្រះរាជអាជ្ញាបានលើកឡើង នូវចំណុចសំខាន់ៗនៃកំណត់ត្រាកិច្ចប្រជុំរបស់គណៈមជ្ឈិម ដែលបង្ហាញពីវត្តមានរបស់ជនជាប់ចោទ រួមមាន លោក **នួន ជា** -លោក **អៀង សារី** និង/ឬ លោក **ខៀវ សំផន** ព្រមទាំងលេខាបក្ស ប៉ុល ពត។[12] បន្ថែមលើនេះ ព្រះរាជអាជ្ញា ស៊ុង ឆវ័ន្ត ក៏បានដាក់បង្ហាញ *"ទង់បដិវត្តន៍"* ដើម្បីឆ្លុះបញ្ចាំងថាថ្នាក់លើមានសមត្ថភាព *"បណ្តុះការប្រើប្រាស់ឧបករណ៍ឃោសនាក្នុងការអប់រំប្រជាពលរដ្ឋទូទៅ។"* បន្ទាប់មកព្រះរាជអាជ្ញាបានបន្តបង្ហាញ ឯកសារដែលជាបទបញ្ជារបស់គណៈមជ្ឈិម និងមន្ទីរ៨៧០ ដែលបញ្ជាក់ថារាល់ការអនុវត្តន៍ ត្រូវតែយោងតាមការណែនាំ។ [13] ព្រះរាជអាជ្ញាជាតិបានបញ្ចប់ការដាក់បង្ហាញឯកសាររបស់ខ្លួនត្រឹមការលើកឡើងនូវទូរសារ ឆ្លើយឆ្លងរវាង មន្ទីរ៨៧០ ឬគណៈមជ្ឈិមបក្ស និងភូមិភាគឧត្តរថ្មីដោយហេតុថា ពួកគេបានកំចាត់ និងបោស សម្អាតខ្មាំងផ្ទៃក្នុង និងក្រៅ។[14]

ជាចុងបញ្ចប់ ព្រះរាជអាជ្ញាអន្តរជាតិ ឃីត រេយ៍ន័រ បានដាក់បង្ហាញឯកសាររបស់ការិយាល័យសហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងប្រព័ន្ធទំនាក់ទំនងនៅថ្នាក់ភូមិភាគ និងបានពន្យល់ពីលំហូរដែលបទបញ្ជា និងព័ត៌មានត្រូវបានបញ្ជូនពីថ្នាក់តំបន់ថ្នាក់ភូមិភាគ និងបន្តទៅថ្នាក់លើ។ លោកព្រះរាជអាជ្ញាបានរៀបរាប់ពីការផ្លាស់ប្តូរព័ត៌មានរវាងភូមិភាគឥសាន និងភូមិភាគបូព៌ា ជាពិសេសតាមរយៈការប្រើប្រាស់ប្រព័ន្ធទូរសារក្នុង *"គោលដៅបោសសំអាតផ្ទៃក្នុង និង ការប្រយុទ្ធប្រឆាំងជាមួយយួន ដែលកើតឡើងទាំងថ្ងៃទាំងយប់។"*[15] ព្រះរាជអាជ្ញាបានបន្តបង្ហាញលម្អិតពីទូរសារដែលរាយការណ៍ទៅ *"មជ្ឈិមបក្ស"* រហូតដល់មេធាវី អាកទួរ វែកគែន ដែលជាមេធាវីការពារក្តីលោក **ខៀវ សំផន** បានធ្វើការជំទាស់។ លោកមេធាវីបានលើកឡើងថា *"ជូនពេលខ្លះ"* ព្រះរាជអាជ្ញាបាន *"សំដៅដល់មជ្ឈិមបក្ស"* ដែលពាក្យនេះ *"គឺមិនយោងទៅលើឯកសារណាមួយទេ។"* ព្រះរាជអាជ្ញា រេយ៍ន័រ បានទទួលស្គាល់នូវចំណុចដែលមេធាវី វែកគែន បានលើកឡើង ហើយគាត់ក៏ឈប់ប្រើពាក្យនេះ។

បន្តមកទៀត ព្រះរាជអាជ្ញាបានលើកនូវឯកសារទំនាក់ទំនងពីភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគពាយព្យទៅអង្គការជាពិសេសពាក់ព័ន្ធនឹងការស៊ើបការ និង ចម្លើយសារភាពរបស់ខ្មាំងសត្រូវនៅក្នុងជួរ។[16] ឯកសារនោះចង់បញ្ជាក់ថា រាល់ទំនាក់ទំនងរវាងភូមិភាគ និងភូមិភាគត្រូវតែឆ្លងកាត់ ប៉ុល ពត ឬ *"អង្គការ"* ឬ មន្ទីរ៨៧០ជាមុន។ [17] ព្រះរាជអាជ្ញា ក៏បង្ហាញពីឯកសារដែលថ្នាក់តំបន់រាយការណ៍ទៅថ្នាក់ភូមិភាគ និងថ្នាក់ ភូមិភាគ ផ្ញើបន្តទៅថ្នាក់លើ[18] និងរបាយការណ៍ពីសហករណ៍ ផ្ញើជូនទៅថ្នាក់ស្រុក។

## ខ. ឯកសារដែលដាក់បង្ហាញដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងការជំទាស់របស់មេធាវីការពារក្តី

ក្រៅពីការដាក់ឯកសារដែលពួកគេមានបំណងប្រើប្រាស់នៅក្នុងសវនាការវគ្គទី៣ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនូវបញ្ហានីតិវិធីមួយចំនួន ដែលពាក់ព័ន្ធនឹងការជូនដំណឹងដល់ភាគីអំពីខ្លឹមសារនៃបញ្ជីឯកសារ។

### ១. ការជូនដំណឹងក្នុងរយៈពេលសមរម្យដល់ភាគី

មុននឹងការដាក់ឯកសារដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីលោក អាង ឧត្តម ជាមេធាវីជាតិការពារក្តីឲលោក **អៀង សារី** បានលើកនូវសំណើមួយពាក់ព័ន្ធនឹងបញ្ជីឯកសាររបស់ ដើមបណ្តឹងរដ្ឋប្បវេណីដាក់ជូនតុលាការ។ លោកមេធាវីបានជម្រាបជូនអង្គជំនុំជម្រះថា បញ្ជីឯកសារចុះថ្ងៃទី១១តុលា រួមមានសេចក្តីថ្លែងការណ៍របស់សាក្សីនានា ដែលជនជាប់ចោទ **អៀង សារី** មិនមានឱកាសក្នុងការតទល់ គឺមានន័យថាគាត់ស្នើសុំឲ្យសហមេធាវីនាំមុខអន្តរជាតិ អេលីហ្សាបេត ស៊ីម៉ុនណូហ្វត មិនគួរប្រើប្រាស់ឯកសារនោះទេ ហើយឯកសារដែលលោកកំពុងសំដៅ គឺមានចំនួនជាង១០ច្បាប់។[19] សហមេធាវីនាំមុខស៊ីម៉ុនណូហ្វត បានឆ្លើយតបថា ក្រុមលោកស្រីបានរៀបចំបញ្ជីបន្ថែមថ្មីដែលមានឯកសារ១៣ច្បាប់ ក្នុងនោះរួមមាន ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបទសម្ភាសន៍នានា ហើយឯកសារទាំងនោះគឺមិនទាក់ទងនឹងអំពើ ឬសកម្មភាពរបស់ជនជាប់ចោទ **អៀង សារី** ទេ។ លោកស្រីបន្តថាមានតែឯកសារ២ច្បាប់ប៉ុណ្ណោះដែល *"អាចនឹងបញ្ហា"* ដល់អង្គជំនុំជម្រះ ប៉ុន្តែលោកស្រីពុំគិតថា ឯកសារទាំងនោះជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់ជនជាប់ចោទ **អៀង សារី** ឡើយ។ ទោះបីជាយ៉ាងណា លោកស្រីមានឆន្ទៈក្នុងការដកឯកសារនោះចេញប្រសិនបើមានការណែនាំពីអង្គជំនុំជម្រះ។

នៅក្នុងបញ្ហានេះមេធាវី អែនឌ្រូ អ៊ីនូហ្វី ដែលជាមេធាវីការពារក្តីលោក **នួន ជា** បានស្នើសុំការបញ្ជាក់ ពីតម្លៃនៃសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ សហមេធាវីនាំមុខស៊ីម៉ុនណូហ្វត បានលើកឡើងដោយការភ្ញាក់ផ្អើលចំពោះការលើកឡើងនេះ និងបានថ្លែងថា៖

> *លោកប្រធាន ខ្ញុំឆ្ងល់ណាស់ហេតុអ្វីបានជានៅតំណាក់កាលនេះទៅហើយ គេនៅតែនិយាយអំពី តម្លៃជាភស្តុតាងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ... ខ្ញុំយល់ឃើញថាមិនមានការគោរពទេក្នុងការ និយាយថាសក្ខីកម្មរបស់រដ្ឋប្បវេណីនេះមិនមានតម្លៃជាភស្តុតាងនោះ។ ការទទួល បានដំណឹងដែលមេធាវីលើកឡើងថាឯកសារទាំងនោះពុំមានតម្លៃជាភស្តុតាងយើងនឹងត្រូវកោះ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះមកផ្តល់សក្ខីកម្មនិងការកំណត់តម្លៃនៃសក្ខីកម្មនឹងត្រូវធ្វើការវាយតម្លៃដោយអង្គជំនុំជម្រះនៅក្នុងពេលសមរម្យមួយ។*

មេធាវី អ៊ីនូហ្វី បានឆ្លើយតបថាសំណើរបស់គាត់ពុំមានចេតនាមិនគោរពដើមបណ្តឹងរដ្ឋប្បវេណីទេគឺគ្រាន់តែចង់ដឹងពីទម្ងន់ដែលអង្គជំនុំជម្រះផ្តល់ដល់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និង

ជនជាប់ចោទតែប៉ុណ្ណោះ *(សូមមើលផ្នែក III.ឝ.១)*។ អង្គជំនុំជម្រះពុំបានធ្វើសេចក្តីសម្រេចចំពោះសំណើសុំការបំភ្លឺរបស់មេធាវីអ៊ីនូហ្ស៊ីទេ ប៉ុន្តែបានលើកឡើងពីបញ្ហារបស់មេធាវី អាង ឧត្តម ដែលពាក់ព័ន្ធនឹងបញ្ជីឯកសាររបស់សហមេធាវីនាំមុខ។

បន្ទាប់ពីបានបកស្រាយថា បញ្ជីឯកសារចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទើបតែផ្ញើចេញ២-៣នាទី នៅមុនពេលការពិភាក្សាដេញដោលនៅថ្ងៃនោះមេធាវី អាង ឧត្តម បានជំទាស់ទៅនឹងបទសម្ភាសន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចំនួន២ច្បាប់ ដោយហេតុថាជនជាប់ចោទ **អៀង សារី** ពុំអាចតតាំងទៅនឹងឯកសារនោះបាន។ សហមេធាវីនាំមុខ ស៊ីម៉ុនណូហ្វត បានបដិសេធនឹងការជំទាស់នោះ និងបានស្នើថាតុលាការមិនគួរចំណាយពេលដោយឥតប្រយោជន៍ជាងនេះទេ និងលើកឡើងថាមេធាវីគួរតែធ្វើការជំទាស់នៅពេលឯកសារនោះ កំពុងដាក់បង្ហាញ។ ក្រោយពីការពិភាក្សាពីរលើកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ បានរំឭកដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា ពួកគេគួរតែជូនដំណឹងដល់ភាគីក្នុងពេលសមរម្យ ហើយបន្តថាអង្គជំនុំជម្រះនឹងយោងតែទៅលើ បញ្ជីឯកសារចាស់ដែលមានចំនួន១៥ច្បាប់ចុះថ្ងៃទី១១តុលា ប៉ុន្តែបទសម្ភាសន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចំនួន២ច្បាប់អាចត្រូវបានដកចេញ ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។មេធាវី ស៊ីម៉ុនណូហ្វត បានបញ្ជាក់ថា *“ជាការពិតណាស់ឯកសារទាំង១៣ច្បាប់គឺដូចគ្នានឹងបញ្ជីឯកសារដែលមានចំនួន១៥ច្បាប់ ដោយគ្រាន់តែឯកសារ២ច្បាប់ទើបតែដកចេញ។”*

## ២. ឯកសារដែលដាក់បង្ហាញដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីសម្រាកអាហារថ្ងៃត្រង់ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានចាប់ផ្តើមដាក់បង្ហាញឯកសាររបស់ខ្លួន។ មេធាវី ពេជ អង្គ ដែលជាសហមេធាវីនាំមុខជាតិបានដាក់បង្ហាញ ខ្សែវីដេអូរជាច្រើនវគ្គ ស្តីពីភាពយន្តឯកសារឈ្មោះ *“សត្រូវរបស់ប្រជាជន”* និង*“រួចជីវិត៖ នៅក្នុងបេះដូងខ្មែរក្រហមដ៏ឆ្កួតលីលា Survive: In the Heart of the Khmer Rouge Madness”* ដែលជាកិច្ចសម្ភាសន៍ជាមួយជនជាប់ចោទ **នួន ជា** និងជនជាប់ចោទ **ខៀវ សំផន** ដោយនិយាយពីទំនាក់ទំនង និងការរាយការណ៍ទៅ ប៉ុល ពត។[20] មេធាវី ពេជ អង្គ បានបញ្ជាក់ថា ប៉ុល ពត និងជនជាប់ចោទ **នួន ជា** បានធ្វើការ និងប្រឹក្សាយោបល់គ្នាយ៉ាងជិតស្និត *“ចំពោះបញ្ហារសើបៗ។”* មេធាវី អ៊ីនូហ្ស៊ី បានជំទាស់ទៅនឹងការចាត់ប្រភេទនៃវីដេអូរ នេះជាលទ្ធផលមេធាវី ពេជ អង្គ ក៏មិនបន្តចាត់ប្រភេទ ឬធ្វើសេចក្តីសន្និដ្ឋានទៅលើខ្សែវីដេអូរទាំងនោះទៀតដែរ។ នៅក្នុងឈុតវីដេអូរជាបន្ត លោក **នួន ជា** បានពិភាក្សាជាមួយ ប៉ុល ពត អំពីកម្មាភិបាល ដែលមិនគោរពវិន័យបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ និង *“ការកម្ទេចតាមលក្ខណៈធម្មជាតិ ពុំមែនតាមបុគ្គល។”* មេធាវី ពេជ អង្គ ក៏បានបង្ហាញឈុតវីដេអូរដែលលោក **នួន ជា** និយាយថាគាត់ជឿជាក់ថា ប៉ុល ពត មិនមែនជាអ្នកសម្លាប់មនុស្សទេ៖

> *គាត់មិនមែនជាអ្នកសម្លាប់មនុស្សទេ។ អ្នកសម្លាប់មនុស្សគឺ ជាជនដែលសម្លាប់មនុស្សស្លូតត្រង់គ្មានកំហុសដោយគ្មានហេតុផល ... ប៉ុល ពត គឺមិនមែនជាឃាតករទេ។ គាត់សម្លាប់តែមនុស្សក្បត់ជាតិ ក្បត់ប្រជាជនឯង និងមនុស្សលក់ទឹកដីឲ្យបរទេស។*

ជាបន្ទាប់មេធាវី វ៉េកគែន បានធ្វើការជំទាស់ និងបានស្នើសុំឲ្យមានការបញ្ជាក់ពីទំនាក់ទំនងរវាងបទសម្ភាសន៍នៅក្នុងវីដេអូរ និងប្រព័ន្ធទំនាក់ទំនងរបស់របបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែសំណើនេះត្រូវបានទាត់ចោលក្រោយពីមេធាវី ពេជ អង្គ បានពន្យល់ថាវីដេអូរនេះបានបង្ហាញ *"រចនាសម្ព័ន្ធទំនាក់ទំនង"* រវាងលោក **នួន ជា** និង ប៉ុល ពត។

មេធាវី ពេជ អង្គ បានបន្តបង្ហាញនូវខ្សែភាពយន្តឯកសារទីពីរ ដែលជាកិច្ចសម្ភាសន៍ជាមួយលោក **ខៀវ សំផន**។ នៅក្នុងឈុតទី១ លោក **ខៀវ សំផន** បាននិយាយថាដំបូងឡើយគាត់មិនបានដឹងថា ប៉ុល ពត មានឋានៈថ្នាក់ខ្ពស់ទេ។ មេធាវី វ៉េកគែន បានជំទាស់ទៅនឹងខ្សែវីដេអូរនេះ និងបានស្នើសុំអង្គជំនុំជម្រះឲ្យទទួលយកខ្សែវីដេអូរនេះ *"នៅសវនាការចុងក្រោយ"* ព្រោះ *"ខ្សែវីដេអូរនេះពុំជាប់ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ ឬការទំនាក់ទំនងទេ។"* មេធាវី ពេជ អង្គ បានពន្យល់ថាលោក **ខៀវ សំផន** បានដាក់ចេញគោលគំនិតថ្មីមួយនៅក្នុងកិច្ចប្រជុំ *"ថាតើត្រូវដំណើរការបែបណា ?"* វីដេអូរនេះក៏បានបង្ហាញពី *"ការចែករំលែកព័ត៌មាន"* នៅក្នុងគណៈមជ្ឈិម។ ជាលទ្ធផល អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសហមេធាវីនាំមុខបន្តបង្ហាញវីដេអូនោះទៀត។ នៅក្នុងឈុតបន្ទាប់បានបង្ហាញថា លោក **ខៀវ សំផន** រីករាយដែលបានដឹងថាបក្សបានទទួលជ័យជំនះដោយរំដោះទីក្រុងភ្នំពេញនៅថ្ងៃទី១៧មេសា១៩៧៥ប៉ុន្តែ គាត់ *"មានការភ្ញាក់ផ្អើលដោយបានដឹងក្រោយមកថា មានបទបញ្ជាស្តីពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ"* ដាក់ចេញដោយថ្នាក់លើ។

នៅពេលមេធាវី ពេជ អង្គ បានដាក់បង្ហាញសារណារបស់លោក **ខៀវ សំផន** ដែលពាក់ព័ន្ធនឹងសហករណ៍[21] មេធាវី វ៉េកគែន បានអះអាងថា សារណានេះពុំជាប់ពាក់ព័ន្ធនឹងបច្ចុប្បន្នភាពនៃសវនាការទេ និងថា ជាការប្រសើរគួរតែត្រូវដាក់នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោល។ មេធាវី ពេជ អង្គ បានពន្យល់ថា ដោយសាគណៈមជ្ឈិមបានដាក់ឲ្យសហករណ៍មានដំណើរការ ដូច្នេះហើយអង្គជំនុំជម្រះក៏គាំទ្រ និងបានអនុញ្ញាតឲ្យមេធាវីបន្តទៀត។ ទោះបីជាមានការជំទាស់ជាបន្តបន្ទាប់ពីមេធាវី គង់ សំអុន ដែលជាមេធាវីជាតិការពារក្តីលោក **ខៀវ សំផន** ក៏អង្គជំនុំជម្រះបានត្រឹមរំឭកដល់ភាគីឲ្យផ្តោតសំខាន់តែពីទំនាក់ទំនងនៅក្នុងតំណាក់កាលនេះ។ សហមេធាវីនាំមុខជាតិបានដាក់បង្ហាញឯកសារចុងក្រោយគឺលក្ខន្តិកៈបក្សកុម្មុយនីស្ត កម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធនឹងរចនាសម្ព័ន្ធបក្សនៅថ្នាក់ស្រុក ថ្នាក់តំបន់ ថ្នាក់ភូមិភាគ និងនៅថ្នាក់លើ។

សហមេធាវីនាំមុខអន្តរជាតិ ស៊ីម៉ុនណូហ្វត បានចាប់ផ្តើមធ្វើបទបង្ហាញខ្លួន ដោយពន្យល់ថានៅឆ្នាំ២០០៦ និងឆ្នាំ២០០៧ មានអ្នកកាសែតម្នាក់បានធ្វើកិច្ចសម្ភាសន៍ជាមួយលោក **នួន ជា** និងលោក **ខៀវ សំផន** ដែលបញ្ជាក់ថា ជនជាប់ចោទទាំងពីរបានបង្ហាញពី *"ទស្សនៈវិស័យរបស់ខ្លួនអំពីរបបរចនាសម្ព័ន្ធមជ្ឈិមនិងតួនាទីខ្លួន។"* នាពេលនោះ ឯកសារមួយចំនួនទៀត ក៏ត្រូវបានដាក់បង្ហាញ រួមមានកំណត់ត្រាក្នុងពេលធ្វើ សម្ភាសន៍ជាមួយលោក **ខៀវ សំផន** ដោយបានលើកឡើងពីតួនាទីគាត់នៅក្នុងគណៈមជ្ឈិម។ មេធាវី វ៉េកគែន បានជំទាស់នឹងការប្រើប្រាស់កំណត់ត្រានេះ ដោយអះអាងថា វាអាចមានភាពមិនត្រឹមត្រូវប្រសិនបើគ្មានខ្សែអាត់សម្លេងនោះទេ។ នាពេលនោះ អង្គជំនុំជម្រះបានច្រានចោលការជំទាស់នោះដោយហេតុថា ភស្តុតាងនេះត្រូវបានទទួលយកជាភស្តុតាងនៅតុលាការហើយ។ ទន្ទឹមនឹងនោះ មេធាវី អ៊ីនូហ្ស៊ី ក៏បានស្នើសុំឲ្យមានការបញ្ជាក់លើចំណុចនេះ។ ប្រធានអង្គជំនុំជម្រះ បានពន្យល់ថាមេធាវីការពារក្តីមានសិទ្ធិជំទាស់នឹង ឯកសារដែលដាក់បង្ហាញដោយភាគីដទៃទៀត ប៉ុន្តែត្រូវរងចាំរហូតដល់បទបង្ហាញរបស់ពួកគេបញ្ចប់ជាមុនសិន។ ជាបន្ទាប់ សហមេធាវីនាំមុខ បានបន្តបទបង្ហាញលើឯកសារ

ដដែលនោះ និងបានដកស្រង់ចំណុចដែលជាប់ពាក់ព័ន្ធនឹងលោក **នួន ជា** ដោយថាជនជាប់ចោទបានពន្យល់ពីតួនាទីរបស់ខ្លួននៅក្នុងផ្នែកអប់រំនិងការកែប្រែសមាសភាពដែល *"ពុំល្អ"*។ សហមេធាវីនាំមុខក៏បានប្រើប្រាស់ឯកសារពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីរបស់ស្ត្រីម្នាក់ដែលជាភរិយារបស់លោក អ៊ុក គេត ជាឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស **សេនេហ្គាល** និងបានត្រឡប់មកកម្ពុជាវិញនៅឆ្នាំ១៩៧៥។ មេធាវី ស៊ីម៉ុនណូហ្វត បានផ្តោតចំឈ្មោះ អ៊ុក គេត និងជនបរទេសជាច្រើន ដែលត្រូវបានយកទៅសម្លាប់នៅមន្ទីរសន្តិសុខទួលស្លែង ចន្លោះពីខែមេសា១៩៧៥ ដល់ខែមករា១៩៧៩។

## គ. ការដាក់ និងការធ្វើបទបង្ហាញលើឯកសារដោយក្រុមមេធាវីការពារក្តី នួន ជា

អង្គជំនុំជម្រះបានកាត់បន្ថយបញ្ជីឯកសាររបស់ក្រុមមេធាវីការពារក្តីលោក **នួន ជា** ដែលជាហេតុនាំឲ្យមានការមិនពេញចិត្តពីសំណាក់មេធាវីក្រុមនេះ ហើយពួកគេបានស្នើសុំការបញ្ជាក់ពីអង្គជំនុំជម្រះ ។ ជាងនេះ មេធាវីការពារក្តី ក៏បានស្នើសុំឲ្យអង្គជំនុំជម្រះផ្តល់ការណែនាំអំពីតម្លៃដែលនឹងផ្តល់ដល់ការសម្តែងមតិយោបល់របស់ជនជាប់ចោទដែលអាចនឹងលើកឡើងចំពោះឯកសារពាក់ព័ន្ធ។

### ១. ការដាក់បង្ហាញឯកសារដោយមេធាវីការពារក្តីលោក នួន ជា

មុនការចាប់ផ្តើមធ្វើបទបង្ហាញឯកសារដោយមេធាវី អ៊ីនូហ្ស៊ី ប្រធានអង្គជំនុំជម្រះ និល ណុន បានជូនដំណឹងថា អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមេធាវីដាក់បង្ហាញឯកសាររបស់លោក ហ្វីលីពស្សត និងឯកសាររបស់លោក ស្ទីវ ហេដឌ័រ ព្រោះថាបុគ្គលទាំងពីរនឹងត្រូវកោះអញ្ជើញឲ្យមកផ្តល់សក្ខីកម្មនាពេលខាងមុខក្នុងនាមជាសាក្សីជំនាញ។ មេធាវី អ៊ីនូហ្ស៊ី បានស្នើសុំការបញ្ជាក់ពីប្រធានតុលាការ ថាតើហេតុអ្វីបានទើបតែជូនដំណឹងគាត់នៅពេលនេះ? ជាដំបូង គាត់ទទួលបានព័ត៌មានថាគាត់អាចដាក់បង្ហាញឯកសារនានាដែលពាក់ព័ន្ធដោយគ្រាន់តែបញ្ជាក់ថាឯកសារនោះមាននៅក្នុងសំណុំរឿង និងមានលេខកូដភស្តុតាង *"E"*។ មេធាវីអ៊ីនូហ្ស៊ី បានថ្លែងថា៖

> *នេះគឺជាលើកទី១ហើយដែលខ្ញុំបានឮអំពីលក្ខខណ្ឌបែបនេះទាក់ទងនឹងការដាក់ឯកសារ។ គេបានជម្រាបយើងថា យើងអាចដាក់ឯកសារណាក៏បានដែលយើងគិតថា វាពាក់ព័ន្ធទៅនឹងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ។ នៅពេលយើងទទួលបានការជូនដំណឹង នៅ ម៉ោង១១ គឺថាពីរនាទីមុនខ្ញុំចាប់ផ្តើមធ្វើបទបង្ហាញនេះគឺថាខ្ញុំមិនអាចដាក់ឯកសារពីរច្បាប់បានទេ។ ខ្ញុំគិតថាវាជាការគួរឲ្យចាប់អារម្មណ៍ជាទីបំផុតទៅលើការណែនាំបែបនេះ។ ខ្ញុំសូមអស់យោបល់។*

ចៅក្រម ឡាវែន៍ បានបញ្ជាក់ថា លោកមេធាវីនឹងមានឱកាសដាក់បង្ហាញឯកសារទាំងនេះ នៅពេលលោក ហ្វីលីពស្សត មកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីជំនាញនៅចំពោះមុខអង្គជំនុំជម្រះដែល *"ប្រហែលជាដើមឆ្នាំ ក្រោយ"* ហើយក៏អាចជាឱកាសក្នុងការពិចារណាដាក់ឯកសាររបស់លោក ស្ទីវ ហេដឌ័រ ថាតើ តុលាការ នឹងធ្វើការកោះអញ្ជើញគាត់ដែរឬយ៉ាងណា?

ដោយសារនៅតែឯកសារតែមួយហើយឯកសារនោះគឺជាកិច្ចសម្ភាសន៍របស់លោក ប៊ែន ឃៀរនិន ជាមួយ សម្តេច ជា ស៊ីម ដែលជាប្រធានព្រឹទ្ធសភាជាតិ និងសម្តេច ហេង សំរិន ដែលជាប្រធានសភា (អ្នកទាំងពីរគឺជាមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលនាពេលបច្ចុប្បន្ន) មេធាវី អ៊ីនូហ្ស៊ី បានស្នើសុំការបញ្ជាក់ថាតើ *"ឯកសារនេះអាចពិភាក្សាបានទេ ឬត្រូវរង់ចាំរហូតដល់លោក ប៊ែន ឃៀរនិន មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ?"* ដោយហេតុថា លោក ប៊ែន ឃៀរនិន អាចនឹងកោះអញ្ជើញមកផ្តល់សក្ខីកម្ម។ នាពេលនោះ ចៅក្រម ឡាវើន៍ បានឆ្លើយតបថាអង្គជំនុំជម្រះផ្តោតសំខាន់តែទៅលើឯកសាររបស់លោក ហ្វីលីពស្ស៊ត និងឯកសាររបស់ ស្ទីវ ហេដឌ័រ។ ដូច្នេះមេធាវី អ៊ីនូហ្ស៊ី ក៏បានដាក់បង្ហាញឯកសារនេះ ដែលដំបូងបង្ហាញ ពីបទសម្ភាសន៍ជាមួយសម្តេច **ហេង សំរិន** និងបានលើកឡើងថាគាត់មានជាប់ពាក់ព័ន្ធនឹងការធ្វើបដិវត្តន៍នៅទីក្រុងភ្នំពេញ និងបានទទួលផែនការអនុវត្តន៍គោលនយោបាយទាំងក្នុង និងក្រៅ។

ជាបន្ទាប់ មេធាវីមានគោលបំណងលើកបញ្ជាក់ថាសេចក្តីសម្រេចឲ្យអនុវត្ត គឺអាចធ្វើបានដោយស្វ័យប្រវត្តិ នៅថ្នាក់កណ្តាល និងថ្នាក់ក្រោម។ ភ្លាមៗនោះ ព្រះរាជអាជ្ញា រេយ៉ន័រ បានធ្វើការជំទាស់ និងលើកឡើងថា មេធាវីការពារក្តីកំពុងព្យាយាមដាក់បង្ហាញឯកសារដែលមិនត្រូវបានទទួលយកនាពេលបច្ចុប្បន្ន។ មេធាវី អ៊ីនូហ្ស៊ី បញ្ជាក់លើបញ្ហានេះថា៖

> *ខ្ញុំគ្រាន់តែសង្ឃឹមថាខ្ញុំអាចធ្វើដូចគ្នា ទាក់ទងនឹងការដាក់ឯកសារនេះ គឺនៅក្នុងពេលធ្វើសវនាការលើឯកសាររបស់រចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា ... ហើយហាក់ដូចជាបញ្ជាក់ថា សាក្សីជាច្រើនរបស់យើងត្រូវបានបដិសេធចោល ប៉ុន្តែពួកយើងនៅតែមិន ច្បាស់ថាហេតុអ្វី បានជាសំណើសុំរបស់យើងត្រូវបានបដិសេធនោះឡើយ យើងមិនទទួលបាននូវការសំអាងហេតុណាមួយទៅលើបញ្ហានេះឡើយ ... ខ្ញុំបានជម្រាបអង្គជំនុំជម្រះកាលពីប៉ុន្មានសប្តាហ៍មុនរួចហើយអំពីការប្រើប្រាស់ឯកសារនេះ ប៉ុន្តែអង្គជំនុំជម្រះមិនបានប្រាប់ទេទើបតែថ្ងៃនេះ បានមកប្រាប់ខ្ញុំថាខ្ញុំមិនអាចប្រើប្រាស់ឯកសារនេះបាន ... ជាថ្មីម្តងទៀតទាក់ទងទៅនឹងការតាមដានទៅលើកំណត់ត្រាប្រតិចារឹក ក៏ដូចជាការប្រើប្រាស់ឯកសារប្រតិចារឹក គឺថាបញ្ហានេះ ត្រូវបានលើកឡើង។*

ប្រធានអង្គជំនុំជម្រះបានបញ្ឈប់មេធាវី អ៊ីនូហ្ស៊ី មិនឲ្យធ្វើសេចក្តីថ្លែងបន្ត និងបានណែនាំថា ពេលវេលានេះ គឺផ្តល់ជូនសម្រាប់តែការធ្វើបទបង្ហាញលើឯកសារភស្តុតាងប៉ុណ្ណោះ។ នាពេលនោះមេធាវី **អ៊ីនូហ្ស៊ី** បានជម្រាបជូនអង្គជំនុំជម្រះថា សហព្រះរាជអាជ្ញាក៏ធ្លាប់ប្រើប្រាស់ឯកសាររបស់លោក ស្ទីវ ហេដឌ័រ កាលពីថ្ងៃទី១០តុលា។ ព្រះរាជអាជ្ញាបានបញ្ជាក់ថាគាត់បានដាក់ឯកសារសង្ខេប ចំនួន២ច្បាប់ពាក់ព័ន្ធនឹងទង់បដិវត្តន៍ដែលរៀបចំដោយលោក ស្ទីវ ហេដឌ័រ ឬលោកសាស្ត្រាចារ្យ ប៊ែន ឃៀរនិន។ ព្រះរាជអាជ្ញាបន្តថាបញ្ហានេះគឺ *"ផ្ទុយស្រឡះ"* ពីរបាយការណ៍កិច្ចសម្ភាសន៍របស់លោក **ស្ទីវ ហេដឌ័រ**។ មេធាវី អ៊ីនូហ្ស៊ី បានទទួលស្គាល់ថាគាត់យល់ពីចំណុចដែលលោកព្រះរាជអាជ្ញាបានលើកឡើងក៏ប៉ុន្តែគាត់នៅតែរក្សាជំហរថា *"ភាគីអាចនឹងអនុវត្តបានល្អជាងនេះ ប្រសិនបើទទួលបានការជូនដំណឹងជាមុនពីដែនកំណត់"* នៃសវនាការ។

## ២. ការផ្តល់តម្លៃចំពោះមតិយោបល់របស់ជនជាប់ចោទចំពោះឯកសារពាក់ព័ន្ធនានា

កាលពីថ្ងៃប្រហស្បតិ៍ នៅមុនការដាក់បង្ហាញឯកសារដោយសហព្រះរាជអាជ្ញា មេធាវី អ៊ីនូហ្សិ បាន ស្នើសុំឲ្យមានការបញ្ជាក់ថាតើអង្គជំនុំជម្រះនឹងផ្តល់តម្លៃដល់មតិយោបល់ដែលលោក **នួន ជា** អាចនឹងលើក ឡើងនៅពេលឯកសារត្រូវបានដាក់បង្ហាញនៅក្នុងសវនាការ។ មេធាវី អ៊ីនូហ្សិ បានដកស្រង់ប្រសាសន៍របស់ លោកស្រីចៅក្រម ខាត់រ៉ាយច៍ នៅថ្ងៃទី៩តុលា២០១២ដែលថា *"សេចក្តីថ្លែងរបស់ជនជាប់ចោទ ពុំអាចយកជាការណ៍ទេ លុះណាតែជនជាប់ចោទពុំអនុវត្តសិទ្ធិនៅស្ងៀម និងព្រមទទួលឆ្លើយសំណួរនានា។"* ប្រការនេះ នាំឲ្យមេធាវី អ៊ីនូហ្សិ បានចោទសួរថាតើវិធាននេះអនុវត្តចំពោះមតិយោបល់របស់ជនជាប់ចោទ ទៅលើឯកសារដែរឬទេ? ចៅក្រម ឡាវែន៍ បានបញ្ជាក់ពីបញ្ហានេះដូចខាងក្រោម៖

> *អង្គជំនុំជម្រះបញ្ជាក់ថាចំណុចជាក់លាក់ដែលលោកស្រីចៅក្រម **ខាត់រ៉ាយច៍** បាន ជម្រាបជូនភាគី គឺនៅតែមានសុពលភាព។ ផ្ទុយទៅវិញអង្គជំនុំជម្រះ សូមជម្រាប ជូនថា ការផ្តល់តម្លៃចំពោះមតិយោបល់ដែលជនជាប់ចោទអាចលើកឡើង គឺដូច ជាភស្តុតាងនានា ដែលនឹងធ្វើការ វាយតម្លៃទៅតាមវិធានផ្ទៃក្នុង។ នៅពេល អង្គជំនុំជម្រះ ចេញសាលក្រមសាលក្រមនោះ នឹងមានបញ្ជាក់នូវហេតុផល ទាំងនោះ។*

នៅថ្ងៃសុក្រនៅពេលដែលមេធាវី អ៊ីនូហ្សិ ចាប់ផ្តើមធ្វើបទបង្ហាញលើឯកសាររបស់ខ្លួនលោកមេធាវី បានជម្រាបជូនអង្គជំនុំជម្រះថា *"ផ្អែកទៅតាមលោក នួន ជា គាត់នឹងមិនផ្តល់មតិយោបល់អ្វីទាំងអស់ចំពោះ ឯកសារនានា។"*

## ឃ. ការដាក់ឯកសារដោយមេធាវីការពារក្តីលោក អៀង សារី

នៅពេលអង្គជំនុំជម្រះផ្តល់វេទិកាដល់ក្រុមមេធាវីការពារក្តីលោក **អៀង សារី** ក្នុងការដាក់បង្ហាញ ឯកសាររបស់ខ្លួន មេធាវី អាង ឧត្តម បានជម្រាបជូនអង្គជំនុំជម្រះថាក្រុមខ្លួនពុំមានឯកសារបន្ថែម និងពុំមាន មតិយោបល់អ្វីទៅលើឯកសារដែលបានដាក់បង្ហាញនោះទេ។ ទោះបីជាយ៉ាងណាលោកមេធាវីបានធ្វើការកត់ សម្គាល់ថា អង្គជំនុំជម្រះគួរតែធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ថាតើឯកសារប្រភេទណាខ្លះ អាចអនុញ្ញាត ឲ្យដាក់បង្ហាញនៅតុលាការ។ មេធាវី អាង ឧត្តម បានបន្តថា នៅថ្ងៃទី១០ តុលា សហព្រះរាជអាជ្ញា បានអាននូវកិច្ចសម្ភាសន៍របស់លោក **អៀង សារី** ដែលធ្វើឡើងដោយលោក ស្ទីវ ហេដឌ័រ ប៉ុន្តែ គាត់ពុំច្បាស់ថាតើគាត់ អាចធ្វើការជំទាស់ទៅលើឯកសារនេះឬយ៉ាងណា? ព្រោះថាឯកសារនោះមាន លេខកូដភស្តុតាង *"E3"*។ ដូច្នេះ ហេតុអ្វីបានជាឯកសារមួយចំនួន ត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញ ចំពោះមុខតុលាការ ប៉ុន្តែឯកសារផ្សេងទៀតពុំអាច? លោកមេធាវីក៏បានអង្អុលបង្ហាញផងដែរថា សហមេធាវី នាំមុខអន្តរជាតិ ស៊ីម៉ុនណូហ្សិត ក៏បានអានឯកសារមួយដែលមានលេខកូដភស្តុតាង *"E"* ដែរ។ ប្រធានអង្គជំនុំជម្រះ បានធ្វើការបញ្ជាក់ចំពោះបញ្ហានេះដូចខាងក្រោម ៖

*ឯកសារពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះបានទទួលយក និងអាចធ្វើការតតាំងនៅក្នុងសវនាការបាន...អង្គជំនុំជម្រះ បានចាត់ចំណាត់ថ្នាក់ឯកសារជាក់លាក់មួយចំនួនជាប្រភេទឯកសារ "E" ហើយឧបសម្ព័ន្ធនៃឯកសារទាំងនោះអាចប្រើប្រាស់បាននៅក្នុងករណីមួយចំនួន ជាពិសេសចំពោះឯកសារពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។*

អង្គជំនុំជម្រះបន្តថាឯកសារដែល *"ពាក់ព័ន្ធនឹងសាក្សីជំនាញ និងឯកសារដទៃទៀត ដែលភាគីមានបំណងដាក់ចំពោះមុខអង្គជំនុំជម្រះ គ្រប់ភាគីគឺអនុញ្ញាតឲដាក់បង្ហាញឯកសារទាំងនេះ នៅក្នុងសវនាការនៅក្នុងពេលសមរម្យមួយ ដែលមានន័យថា ជាការជួយសម្របសម្រួលដល់លំហូរសវនាការ។"*

## ១. ការដាក់ឯកសារដោយមេធាវីការពារក្ដីលោក ខៀវ សំផន

នៅពេលទទួលបានឱកាសដាក់បង្ហាញឯកសារ មេធាវី វែកគែន បានរិះគន់អង្គជំនុំជម្រះចំពោះការចេញសេចក្ដីសម្រេចដែលពុំច្បាស់លាស់ និងការជូនដំណឹងដល់ភាគីក្នុងពេលវេលាមួយមិនសមស្របចំពោះការកែប្រែសេចក្ដីសម្រេចរបស់ខ្លួនដែលពាក់ព័ន្ធនឹងគោលបំណងនៃសវនាការលើឯកសារ។

*បញ្ហាសម្រាប់ក្រុមមេធាវីការពារក្ដីលោក **ខៀវ សំផន** នោះគឺថា អស់រយៈពេល ២ថ្ងៃមកហើយ ដែលយើងបានចាកចេញពីដែនកំណត់នៃសវនាការ។ តាមពិតទៅ ប្រធាន អង្គជំនុំជម្រះ! អ្វីដែលកើតឡើងចំពោះមុខយើងរយៈពេលប៉ុន្មានថ្ងៃនេះ មិនមែន ជាការជំនុំជម្រះក្ដីទេ គឺជាសន្និសិតកាសែតទៅវិញ។ ហេតុនេះហើយ បានជាមេធាវី ការពារក្ដីលោក **ខៀវ សំផន** បដិសេធមិនចូលរួមនៅក្នុងសវនាការបែបនេះ។*

លោកមេធាវី បានបន្តពន្យល់ពីមូលហេតុ ដែលគាត់ពុំមានចេតនាក្នុងការចូលរួមសវនាការយ៉ាងដូច្នេះថា *"យើងមិនចង់ចូលរួមនៅក្នុងសវនាការបែបនេះតទៅទៀតទេ យើងនៅក្នុងដំណើរការដែលសិទ្ធិរបស់ជនជាប់ចោទមិនត្រូវបានគោរព ដូច្នេះយើងមិនចង់ចូលរួមទេ"*។ មេធាវី វែកគែន បានបន្ថែមថាគាត់ទទួលបានព័ត៌មានដំបូងឡើយថា *"យើងនឹងមិនត្រូវបានអនុញ្ញាតឲធ្វើការឆ្លើយតបទេ"* ហើយថា *"យើងក៏មិនចាំបាច់ពិភាក្សាអំពីការទទួលយក ហើយក៏មិនពិភាក្សាអំពីតម្លៃជាភស្តុតាងនៃឯកសារនោះដែរ។"* មេធាវី វែកគែន បានបន្តថា ទោះជាយ៉ាងនេះក្ដី ក្រោយមកលោកប្រធានបែរជាកែប្រែសេចក្ដីសម្រេចរបស់ខ្លួនទៅវិញ៖ *"អង្គជំនុំជម្រះបានកែប្រែវិធាននៃសវនាការ ប៉ុន្តែយើងមិនទាន់ត្រៀមខ្លួន យើងមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ ហេតុដូច្នេះពួកយើងក៏ពុំគួរត្រូវបានសួរឲធ្វើការឆ្លើយតបទៅនឹងឯកសារដែលបានបង្ហាញដោយភាគីនោះដែរ។"* មេធាវី អ៊ីនូហ្ស៊ី បានធ្វើការគាំទ្រចំពោះការលើកឡើងរបស់មេធាវី វែកគែន ហើយគាត់បានបញ្ជាក់ថា *"ការប្រើពាក្យសន្និសិតការសែតគឺសមរម្យណាស់ ដោយសារវាគ្រាន់តែជាការបង្ហាញឯកសារដោយសាមញ្ញ និងគ្រាន់តែជាការធ្វើដោយគ្មានការផ្ដល់យោបល់ និងធ្វើដោយគ្មាននូវកិច្ចពិភាក្សាវែកញែក។"* មេធាវី អ៊ីនូហ្ស៊ី បានធ្វើការសន្និដ្ឋានថា៖

> *ដូច្នេះ លោកប្រធានកាលពីព្រឹកមិញនេះបានជូនដំណឹងមកខាងយើងខ្ញុំថានេះ គឺជា ការជំនុំជម្រះក្តីមួយ។ ខ្ញុំគិតថាអ្វីដែលលោកប្រធានលើកឡើង វាគួរឲ្យភ្ញាក់ផ្អើលណាស់។ លោកប្រធាន គឺពិតជាចៅក្រមមួយរូបដែលអស្ចារ្យ។*

ជាការឆ្លើយតបព្រះរាជអាជ្ញា រេយ៍ន័រ និងសហមេធាវីនាំមុខ ពេជ អង្គ បានផ្តល់និយមន័យថា សវនាការលើឯកសារ គឺជាការដាក់បង្ហាញឯកសារដែលពាក់ព័ន្ធចំពោះមុខអង្គជំនុំជម្រះ។ មេធាវី វ៉ែក គែន បានលើកឡើងថាលោកស្រី ស៊ូហ្សាន ឡេម ជាមន្ត្រីជាន់ខ្ពស់តុលាការបានជូនដំណឹងថា *"សវនាការលើឯកសារមិនទាក់ទងទាំងការដាក់ឯកសារ ឬការពិភាក្សាអំពីតម្លៃភស្តុតាងទេ ... សវនាការនេះ គឺមានគោលបំណងឲសាធារៈជន ដឹងអំពីឯកសារដែលនឹងប្រើប្រាស់នៅក្នុងតុលាការ។"* ប្រធានអង្គជំនុំជម្រះ និល ណុន បានធ្វើការបញ្ជាក់ជាថ្មីថាភាគីអាច *"ធ្វើការកត់សម្គាល់ទៅលើការដាក់ឯកសារជាក់លាក់មួយចំនួន ... ភាគីមិនអាចវិភាគវាយតម្លៃតម្ងន់នៃភស្តុតាង ឬពិចារណាលើភស្តុតាងដូចនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនោះទេ។"*

## IV. **ការគ្រប់គ្រងសវនាការ**

សប្តាហ៍នេះ អង្គជំនុំជម្រះ បានប្រឈមនឹងបញ្ហាជាច្រើនជាពិសេសបញ្ហាច្បាប់ និងនីតិវិធីដែលពាក់ព័ន្ធនឹងសវនាការលើឯកសារ។ អង្គជំនុំជម្រះ បានខិតខំព្យាយាមពន្លឿននីតិវិធីសវនាការដោយណែនាំភាគីឲ្យ ផ្តល់តែមតិយោបល់ដែលពាក់ព័ន្ធ និងធ្វើកំណត់សម្គាល់ខ្លីៗតាមដែលអាចធ្វើបាន ព្រោះអាចធ្វើឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចលើបញ្ហាដែលភាគីបានលើកឡើង។ នៅថ្ងៃព្រហស្បតិ៍អង្គជំនុំជម្រះបានច្រានចោល សំណើរបស់មេធាវី សុន អារុណ ពាក់ព័ន្ធនឹងយាងចូលទីវង្គត់របស់អតីតព្រះមហាក្សត្រខ្មែរ **សម្តេច នរោត្តម សីហនុ** (ព្រះបិតាជាតិ) កាលពីថ្ងៃទី១៥ តុលា ២០១២។ អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ថាការលើកឡើងនេះមិនសមហេតុផលទេ។ ជាងនេះ អង្គជំនុំជម្រះក៏បានជូនដំណឹងថាដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ រងចាំការកោះហៅឲ្យចូលផ្តល់សក្ខីកម្មបន្ទាប់ពីសវនាការលើឯកសារត្រូវបានបញ្ចប់។

## ក. **វត្តមាន**

ជនជាប់ចោទ **អៀង សារី** បន្តនៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ពេញមួយសប្តាហ៍នេះ។ ទោះបីជាយ៉ាងណា សវនាការនៅតែបន្តប្រព្រឹត្តទៅ ដោយសារតុលាការបានទទួលលិខិតលះបង់សិទ្ធិមិនចូលរួមសវនាការរបស់ជនជាប់ចោទ។[22] ចំណែកឯជនជាប់ចោទ **នួន ជា** ក៏ដូចជាសព្វមួយដងបានស្នើសុំទៅតាមដាននៅបន្ទប់រងចាំខាងក្រោមជារៀងរាល់រសៀល ព្រោះតែបញ្ហាសុខភាពរបស់គាត់។ មានតែជនជាប់ចោទ**ខៀវ សំផន** ប៉ុណ្ណោះ ដែលបានបន្តតាមដាន និងចូលរួមសវនាការពេញមួយសប្តាហ៍នេះ។

**វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖** សវនាការនាថ្ងៃនីមួយៗ មានវត្តមានដើមបណ្តឹងរដ្ឋប្បវេណីប្រមាណជា ១០រូបនៅក្នុងបន្ទប់សវនាការ ហើយក្នុងនោះក៏មានដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិមូស្លីមចូលរួមផងដែរ។

**វត្តមានរបស់ភាគី៖** គ្រប់បណ្តាភាគីមានវត្តមាននៅក្នុងសវនាការលើកលែងតែមេធាវី កាណាវ៉ាស ដែលជា មេធាវីការពារក្តីលោក **អៀង សារី** បានអវត្តមានពេញមួយសប្តាហ៍ និងមេធាវី សុន អារុណ ដែលជាមេធាវីការពារក្តីលោក **នួន ជា** បានអវត្តមាននៅរសៀលថ្ងៃសុក្រ។

**វត្តមានសាធារណជន៖**

| កាលបរិច្ឆេទ | សវនាការពេលព្រឹក | សវនាការពេលរសៀល |
|---|---|---|
| ថ្ងៃព្រហស្បតិ៍ ១៨/១០/១២ | ▪ សាធារណជនចូលរួមប្រមាណជា២៣០នាក់ រួមមាន ជនជាតិចាមដែលមកពីស្រុកបារាយ ខេត្តកំពង់ធំ។ | ▪ ជនជាតិចាមដែលតាមដានសវនាការនាពេលព្រឹក បានត្រឡប់ទៅវិញ គឺនៅប្រជាជនតែ១០០នាក់ និង ជនបរទេសចំនួន៧នាក់។ |
| ថ្ងៃសុក្រ ១៩/១០/១២ | ▪ សាធារណជនប្រមាណជា ១៤០នាក់រួមមាន ព្រះសង្ឃ និងដូនជីមកពីខេត្តកំពត និងខេត្តតាកែវ។ | ▪ ប្រជាជនប្រហែលជា១០០នាក់មកពី ខេត្តកំពង់-ចាម។ |

## ខ. ការគ្រប់គ្រងពេលវេលា

អង្គជំនុំជម្រះបានចាប់ផ្តើមសវនាការវិញនៅថ្ងៃប្រហស្បតិ៍សប្តាហ៍នេះ និងដំណើរការរហូតដល់ថ្ងៃសុក្របន្ទាប់ពីបានផ្អាកដំណើរការនីតិវិធីសវនាការកាលពីថ្ងៃប្រហស្បតិ៍សប្តាហ៍មុនដើម្បីចូលរួមប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ។ ទោះបីជាមានការជំទាស់ និងការលើកទឡ្ហីករណ៍ជាបន្តបន្ទាប់ ក៏សវនាការលើឯកសារបានបញ្ចប់មុនការគ្រោងទុកដោយសារតែក្រុមមេធាវីការពារក្តីពុំបានដាក់ឯកសារបន្ថែម លើកលែងតែក្រុមមេធាវីការពារក្តីលោក **នួន ជា** ដែលដាក់ បន្ថែមឯកសារមួយច្បាប់។ ជាបន្ទាប់អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ នៅរសៀលថ្ងៃសុក្រ។ ភាគីបានបញ្ចប់ការសួរដេញដោលលើដើមបណ្តឹងរូបនេះនាថ្ងៃដដែលនោះ ប៉ុន្តែដោយសារពេលវេលាមានកំណត់អង្គជំនុំជម្រះ ក៏បានលើកសេចក្តីថ្លែងការណ៍រៀបរាប់ពីទុក្ខសោកនិងការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅថ្ងៃច័ន្ទសប្តាហ៍ក្រោយ (២២តុលា)។

## គ. នីតិវិធីនៅក្នុងបន្ទប់សវនាការ

នៅពេលមានការតទល់គ្នាយ៉ាងខ្លាំងនៅក្នុងសវនាការ បានបណ្តាលឲ្យភាគីបានប្រើពាក្យសម្តីធ្ងន់ៗ និងសម្តែងការមិនពេញចិត្តរបស់ខ្លួនជាពិសេសនៅពេលដែលមេធាវី វែកគែន និងមេធាវី អ៊ីនួហ្សិ បានលើកឡើងថាសវនាការលើឯកសារគឺជា *"សន្និសិតកាសែត"* (*សូមមើលផ្នែកទីIII.ខ*)។ ជាការឆ្លើយតបសហមេធាវីនាំមុខ ពេជ អង្គ បានថ្លែងថាការលើកឡើងនេះ *"ពុំសមហេតុផលទេ"* ចំណែកឯព្រះរាជអាជ្ញា

រយ៉េន័រ បានបន្ថែមថា *"សវនាការនេះគឺជាការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះ ពុំមែនជាសន្និសិតកាសែតនោះទេ ... ខ្ញុំមានការមិនពេញចិត្ត ដែលមេធាវីការពារក្តីបានលើកឡើងថា 'វាជាឆាកល្ខោន និងជាការសម្តែងនោះ'។"*

ជាងនេះទៀត នាសប្តាហ៍នេះ ការប្រឈមរវាងអង្គជំនុំជម្រះ និងមេធាវី អ៊ីនូហ្ស៊ី បានកើតឡើងយ៉ាងក្តៅគគុក។ អង្គជំនុំជម្រះបានបញ្ឈប់លោកមេធាវីមិនឲ្យធ្វើការកត់សម្គាល់ និងបញ្ចេញមតិយោបល់ជាច្រើនលើកច្រើនសារ តាមរយៈការកាត់ផ្តាច់ប្រព័ន្ធសម្លេង (ម៉ៃក្រូហ្វូន)។ មេធាវី អ៊ីនូហ្ស៊ី នៅតែបន្តប៉ុនប៉ងលើកឡើងសំណើខ្លួន ទោះបីជាប្រព័ន្ធបំពងសម្លេងត្រូវបានកាត់ផ្តាច់ក៏ដោយ គឺគាត់នៅតែក្រោកឈរសុំការអនុញ្ញាតសុំថ្លែងជាបន្ត។ ប្រធានអង្គជំនុំជម្រះ និល ណុន បានធ្វើការណែនាំដល់លោកមេធាវីដោយលើកថាមុន នឹងដាក់សំណើមេធាវីត្រូវលើកឡើងពីកម្មវត្ថុនៃសំណើជាមុនសិន ដែលការធ្វើបែបនេះគឺដើម្បី *"បញ្ចៀសនូវសេចក្តីថ្លែងការណ៍របស់មេធាវី អ៊ីនូហ្ស៊ី ដែលអាចជាការទិតៀនដល់ដំណើរការនីតិវិធី និងប្រធានអង្គជំនុំជម្រះ។"*

នៅថ្ងៃសុក្រមេធាវី អ៊ីនូហ្ស៊ី បានហៅប្រធានអង្គជំនុំជម្រះថា *"ជាចៅក្រមដែលអស្ចារ្យ"* (*សូមមើលផ្នែកទី III.ខ*) ដែលចៅក្រម ឡាវ៉ែន បានធ្វើការកត់សម្គាល់ថា ការលើកបែបនេះគឺជាការ *"មើលងាយ មិនគោរព ... និងជាការប្រមាថ។"* អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចពី *"ការប្រព្រឹត្តកំហុសវិជ្ជាជីវៈ"* យោងតាម វិធាន៣៨នៃវិធានផ្ទៃក្នុង។ ដូច្នេះមេធាវី អ៊ីនូហ្ស៊ី បានព្យាយាមបន្ទន់ឥរិយាបថ ដោយលើកឡើងថា៖ *"ខ្ញុំមិនមានចេតនាប្រមាថមើលងាយដល់ដំណើរការនីតិវិធីទេ។ ខ្ញុំសូមអភ័យទោសប្រសិនបើអ្វីដែលខ្ញុំ លើកឡើងគឺជាការប្រមាថមើលងាយ។"*

## **ឃ. បញ្ហានៃការបកប្រែ និងបញ្ហាបច្ចេកទេស**

បញ្ហាប្រព័ន្ធបំពងសម្លេងបានកើតឡើងនាសប្តាហ៍នេះនៅពេលសហមេធាវីនាំមុខ លោក ពេជ អង្គ បានដាក់បង្ហាញភាពយន្តឯកសារអំពីកិច្ចសម្ភាសន៍របស់លោក **នួន ជា** ។ បញ្ហាផ្សេងទៀតគឺថា អ្នកបកប្រែមិនអាចបកប្រែទាន់នូវអ្វីដែលលោកស្រីមេធាវី ស៊ីម៉ុនណូហ្វត បានលើកឡើងក្នុងកំឡុងពេលធ្វើបទបង្ហាញលើឯកសារឡើយ ប៉ុន្តែទោះបីជាយ៉ាងណា បញ្ហានេះត្រូវបានដោះស្រាយ ដោយអ្នកបកប្រែបានស្នើសុំអង្គជំនុំជម្រះ ឲ្យធ្វើការណែនាំលោកស្រីមេធាវីឲ្យនិយាយឡើងវិញ និងយឺតៗ។

## **ង. តារាងពេលវេលា**

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃព្រហស្បតិ៍ ១៨/១០/១២ | ៩.០១ | ១០.៤១-១១.០១ | ១២.០៥-១៣.៣៥ | ១៤.៤០-១៥.១១ | ១៦.០៦ | ៤ ម៉ោង និង ៤៤ នាទី |
| ថ្ងៃសុក្រ ១៩/១០/១២ | ៩.០៥ | ១០.២៥-១០.៥៤ | ១២.០០-១៣.៤៥ | ១៤.៣៨-១៥.០០ | ១៦.២៦ | ៤ ម៉ោង និង ៤៦ នាទី |

| | |
|---|---|
| រយៈពេលសវនាការជាមធ្យម | ៤ ម៉ោង និង ៤៥ នាទី |
| រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ | ៩ ម៉ោង និង ៣០ នាទី |
| ចំនួនសរុបនៃម៉ោង ថ្ងៃ និង សប្តាហ៍ នៃសវនាការ | ៥២៣ ម៉ោង និង ៤៩ នាទី |
| រយៈពេលសវនាការចំនួន ១១៩ថ្ងៃ អំឡុងពេល ៣៦ សប្តាហ៍ | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

EAST-WEST CENTER

AIJI TRIAL MONITORING

WAR CRIMES STUDIES CENTER
UNIVERSITY OF CALIFORNIA, BERKELEY

[*] AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of **KRT TRIAL MONITOR** was authored by Faith Suzzette Delos Reyes, Daniel Mattes, Hava Mirell, Kimsan Soy, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] Yim Sovann was first examined by Civil Party Lawyer Sam Sokon, followed by International Civil Party Lead Co-Lawyer Ms. Elisabeth Simonneau-Fort. Civil Party was then questioned by Prosecutor Keith Raynor. None of the defense lawyers posed any questions to the Civil Party.

[2] Yim Sovann actually witnessed this "measure" by Orussey Market, where soldiers shot the lock off a door and then proceeded to shoot the residents who were hiding inside.

[3] Pouthi Ban Village is located in Kaoh Thum District in Kandal Province. Yim Sovann worked in a female unit in Pouthi Ban until she was evacuated again in November 1975.

[4] The Civil Party could only recall seeing the transport of individuals by boat once. She estimated that there were about five or six people in the boat and explained that she knew those people were accused of being enemies because "that's why their hands were tied to their backs."

[5] Spelled phonetically.

[6] According to the Civil Party, those at Security Center 7 were placed under close surveillance but were still allowed to work. Sometimes they were arrested for reeducation and, if they improved, they were released. However, people who did not improve or committed some other offense were sent to Security Center 8, where treatment was miserable and prisoners were "handcuffed, shackled, and severely tortured." The Civil Party also recalled witnessing an incident right before the liberation by the Vietnamese when individuals from Svay Rieng Province, with their hands tied behind their backs, marched to Security Center 8, where they were ultimately executed.

[7] On 8 October 2012, the Trial Chamber issued a memorandum approving the inclusion of the killings of Lon Nol soldiers at Toul Po Chrey immediately after the evacuation of Phnom Penh within the scope of trial in Case 002/01. See Trial Chamber. "Notification of Decision on Co-Prosecutor's Request to Include Additional Crime Sites within the Scope of Trial in Case 002/01 (E163) and deadline for submission of applicable law portion of Closing Briefs," (8 Oct. 2012). E163/5. Paragraph 3.

[8] Prosecutors Dale Lysak and Seng Bunkheang initiated the OCP presentation of documents last Wednesday, 10 October 2012. Lysak outlined the presentation; Seng Bunkheang spoke about documents related to the Standing Committee and the Central Committee. Lysak returned to focus on communication and implementation of Standing and Central Committee policies. At the end of 10 October, Vincent de Wilde d'Estmael began his part of the presentation, related to the formation and composition of the DK government and its ministries. On Thursday, 18 October, de Wilde d'Estmael continued with this line of presentation. National Prosecutor Song Chorvoin provided further documentary evidence, and Prosecutor Keith Raynor followed and concluded the OCP presentation. National CPLCL Pich Ang then began presenting documents for the Civil Parties and was subsequently followed by International CPLCL Elisabeth Simonneau-Fort.

[9] The prosecutor referred to documents D366/7.1.351, dated 7 January 1978; D366/7.1.487, dated 7 March 1977; and IS 18.68, dated 4 November 1978.

[10] Regarding the elimination of internal enemies, the Prosecutor referred to documents E3/1159, E3/522, E3/808, and E3/153.

[11] In regards the Ministry of Social Affairs, the Prosecutor referred to E3/226 and E3/808.

[12] Ms. Song Chorvoin referred to three records of Standing Committee meetings in documents E3/182; E3/232; E3/216. She also referenced a "speech by Mr. Khieu Samphan during Anniversary of 16 April 1977," in document E3/200.

[13] The issue of Revolutionary Flag referenced was dated Feb/March 1976 (E3/166). The Prosecutor also referred to a decision by the Standing Committee dated 30 March 1976 (E3/12), and an instruction by Office 870 (E3/160).

[14] In reference to this subject, Ms. Song Chorvoin referred to documents E3/727; E3/1150; E3/241; E3/1091; E3/1144; E3/1073; E3/801.

[15] This quote comes from a telegram from Vi, Northeast Zone Secretary, to "respected Brother," document E3/319. Additionally, Raynor referred to other telegrams sent to the "Party Center" in documents from the Northeast and East Zones in E3/1122; E3/943; E3/1191; E3/1192; E3/257; E3/879; E3/871; E3/892.

[16] Specifically, document E3/1092, but Raynor also presented E3/769; E3/1094, E3/1179; E3/951.

[17] The prosecutor was referring to documents E3/1096, E3/1679, E3/956, E3/501, respectively.

[18] Mr. Raynor referred to documents dated May 1977, E3/179 and E3/180.

[19] Mr. Ang Udom cited an email from the Trial Chamber's Senior Legal Officer on 10 October, 2012, in which the Chamber reminded the Civil Parties of a previous decision, found in document E96/7, which stated that written statements, when presented instead of oral ones, would be inadmissible if they went to the acts and conduct of the accused, thus Parties should present documents with attributable probative value and weight.

[20] These two documentary films had document numbers E166/8R and E109/2.3R, respectively.

[21] The thesis referenced by Pich Ang bears document number E3/123.

[22] In accordance with Internal Rule 81 (1) and Articles 14 (1) and 14 (3) (d) of the International Covenant for Civil and Political Rights, Accused Ieng Sary issued a Limited Waiver, agreeing to waive his direct presence in the courtroom for 1 Civil Party and 7 witnesses. He explicitly stated that he is not waiving his right to be present for other witnesses. See Ieng Sary. "Limited Waiver" (18 September 2012). E229. Due to his extended stay in the hospital, he subsequently issued another Limited Waiver for 11 additional witnesses and 7 Civil Parties. See Ieng Sary. "Limited Waiver" (1 October 2012). E237.